**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
# កិច្ចប្រជុំរួមប្រចាំខែកញ្ញា ឆ្នាំ២០២១
# របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកញ្ញា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្តាញវីដេអូ កម្មវិធី Zoom សរុបចំនួន៤៥នាក់/គណនី។

**គោលបំណងនៃកិច្ចប្រជុំដើម្បី ៖**

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និងការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ វាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គក្នុងការអនុវត្តផែនការសកម្មភាពនិងដាក់ផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម យិនដារ៉េត អគ្គលេខាធិការ។

២) បទបង្ហាញស្តីពីអាទិភាពនៃការសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយឯកឧត្តម **ទា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣) មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី។

៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកញ្ញា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែតុលា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

**I- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

### ១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានរៀបចំរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ជូនរាជរដ្ឋាភិបាល។
- វគ្គបណ្តុះបណ្តាលលើកទី២ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ប្រព័ន្ធថវិកាជាតិ។
- សិក្ខាសាលាបណ្តុះបណ្តាលស្តីពីជំនាញទន់ (Soft Skills)
- កិច្ចប្រជុំ ស្តីពីផលប៉ះពាល់នៃការឆ្លងរាលដាលកូវីដ-១៩ក្នុងសហគមន៍លើការធ្វើតេស្តឈាមរកមេរោគអេដស៍។
- កិច្ចប្រជុំស្តីពីការជំរុញការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍
- ប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ ដើម្បីបានព័ត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM- TG, FEW និងការអនុវត្ត PrEP។
- រៀបចំកែសម្រួល TRC សម្រាប់ត្រីមាសទី៣ ដើម្បីស្នើសុំអនុវត្តសកម្មភាពមូលនិធិសកលឡើងវិញ បន្ទាប់ពីកូវីដ-១៩ធូរស្បើយ។

### ២- បញ្ហាប្រឈម ៖

- ការអូសបន្លាយនៃការរាតត្បាតមេរោគកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការធ្វើអន្តរាគមន៍ និងការប្រមូលព័ត៌មាននៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ព័ត៌មានហិរញ្ញប្បទានក្នុងការផ្តល់សាច់ប្រាក់របស់រាជរដ្ឋាភិបាល។

### ៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ចុះអភិបាលតាមបណ្តាខេត្តនានា។
- បន្តរៀបចំផែនការសកម្មភាពថវិកា និងអនុវត្តសកម្មភាពសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ក្រសួង ស្ថាប័ន ពិសេស*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (FTC)។
- ការរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ រៀបចំសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២១។
- គោលការណ៍ស្នើសុំជានាចំណាយលើគម្រោងសិក្សាស្រាវជ្រាវ អំពីការបង្កើតសន្ទានុក្រមស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស

## II- បទបង្ហាញស្តីពីការដឹកនាំដើម្បីបញ្ចប់ការរាលដាលជំងឺអេដស៍នៅកម្ពុជា

ឯកឧត្តមវេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកបច្ចេកទេស បានបង្ហាញពីអាទិភាពនៃការសម្របសម្រួលក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៖

- ត្រូវមានវិធានការប្រទាក់ក្រឡាគ្នារវាងការបង្ការ ការស្វែងរកអ្នកឆ្លងដើម្បីព្យាបាល និងប្រើប្រាស់ថ្នាំឱ្យបានជាប់លាប់។
- កត្តាជោគជ័យក្នុងការទប់ស្កាត់ការរាតត្បាតឱ្យបាន៩៥%នៅឆ្នាំ២០២៥។
- ការអភិវឌ្ឍន៍វិស័យសុខាភិបាលតាមគម្រូ 4s របស់ GFATM។
- មន្ត្រីទាំងអស់ត្រូវមានជំនាញទន់ (Soft Skills)ក្នុងការដឹកនាំ និងគ្រប់គ្រង។ ក្នុងនោះ អ្នកដឹកនាំត្រូវចាប់ផ្ដើមមើលទៅលើ សីលធម៌ និងក្រមសីលធម៌នៅក្នុងអ្នកដឹកនាំ។
- ត្រូវបញ្ចប់ការរីករាលដាលមេរោគអេដស៍ ដោយប្រើចរន្តជាតិតែមួយ និងពង្រឹងប្រព័ន្ធការអនុវត្តន៍កម្មវិធី។
- ត្រូវប្រើប្រាស់ចំណុចគោលដៅសកល២០២៥ ក្នុងការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រ។
- ត្រូវយកសេចក្ដីសម្រេច ស.ជ.ណ. ២១៣ មកអនុវត្ត។
- ត្រូវពង្រឹងប្រព័ន្ធថ្នាក់ក្រោមជាតិគាំទ្រកម្មវិធី។
- ត្រូវពង្រឹងស្ថាប័នឆ្លើយតបនឹងមេរោគអេដស៍។

## III)- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ក្នុងបរិបទនៃជំងឺកូវីដ-១៩ មន្ត្រីរាជការអាចចុះបេសកកម្មបានដោយប្រើថវិកាមូលនិធិសកល (GF) ដោយគោរពនូវវិធានការសុខាភិបាល ៣ការពារ ៣កុំ។ វាជាភ័ព្វសំណាងរបស់ប្រជាជនកម្ពុជាដែលបានចូលរួមចាក់វ៉ាក់សាំងបានច្រើន យើងត្រូវបន្តប្រុងប្រយ័ត្នខ្ពស់ ដោយត្រូវចេះផ្លាស់ប្ដូរទម្លាប់រស់នៅរបស់ខ្លួនឱ្យស្របតាមពាក្យស្លោក "*រៀនរស់នៅជាធម្មតាជាមួយវីរុស កូវីដ-១៩ តាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*"។

២- ឯកឧត្តម **ទា ផលា** និងឯកឧត្តម ឈឹម ឃិនដារ៉េត ត្រូវបន្តរៀបចំកិច្ចប្រជុំជា មួយគណៈកម្មាធិការអេដស៍ក្រសួងមហាផ្ទៃ ដើម្បីឱ្យគាត់ណែនាំដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងបន្តទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ពីកញ្ចប់ផែនការសកម្មភាពថវិកា៨០លានរៀល។

៣- ចំពោះអង្គការក្រៅរដ្ឋាភិបាល (NGOs) ឬអង្គការសង្គមស៊ីវិល (CSOs) ដោយសង្កត់ធ្ងន់លើការ***ពង្រឹងប្រព័ន្ធជាតិ*** (strengthening country system) ដើម្បីមកធ្វើការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។ រៀបចំ National data base មួយ ដែលមាន Health & non health information input (ID poor.., )។

៤- ឯកឧត្តម **ឈឹម ឃិនដារ៉េត** ត្រូវបន្តរៀបចំកិច្ចប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងមហាផ្ទៃ ដើម្បីឱ្យ គាត់ណែនាំដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ស្រុក ខណ្ឌ និងឃុំ សង្កាត់គ្រប់រាជធានី ខេត្ត និងធ្វើផែនការថវិកា។ ជំរុញការងារប្រយុទ្ធនឹងជំងឺអេដស៍ឱ្យល្អប្រសើរឡើង ពិសេសអំពី*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* ( Fast Track City)។ ត្រូវបន្តទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីថវិកា ៨០លានរៀល ផ្ដល់ជូនទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ប្រធានលេខាធិការដ្ឋាន ដើម្បីមានថវិកាសម្រាប់ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍។

៥- ត្រូវបន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន រាជធានី/ខេត្ត ដោយណែនាំពីសកម្មភាពដែលគាត់ត្រូវតែធ្វើ និងផ្ញើរបាយការណ៍មកឱ្យអ.ជ.ប.ជ.អទាន់ពេលវេលាក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ដើម្បីទទួលបានការលើកទឹកចិត្តនិងប័ណ្ណសរសើរពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ គឺយកថ្ងៃទី២០ ខែធ្នូ និងសន្និបាតនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ បើសភាពការណ៍មិនទាន់អនុគ្រោះ ធ្វើតាមបណ្តាញវីដេអូ កម្មវិធី Zoom ពីម៉ោង៨:០០-១២:០០នាទីព្រឹក។

៦- ត្រៀមផ្តល់រង្វាន់ដោយវាយតម្លៃលើទី១) មានរបាយការណ៍ ទី២) របាយការណ៍ផ្តល់ជូនទាន់ពេលវេលា ទី៣) ស្ថាប័ន បានរៀបចំគណៈកម្មាធិការអេដស៍ និងបានប្រជុំគណៈកម្មាធិការអេដស៍ដែរឬទេ ទី៤) មានផែនការសកម្មភាពឬទេ(ចំគោលដៅឬទេដូចជាសម្របសម្រួលកិច្ចប្រជុំជាន់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍) ទី៥ បានលើកផែនការថវិកាឬទេ (ខេត្ត FTC ៨០លាន) និងទី៦) មានសហការជាមួយអង្គការសង្គមស៊ីវិលឬទេ។

៧- និតិវិធីកំណត់លក្ខណសម្បត្តិនៃការផ្តល់រង្វាន់ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្តៈ

- បានពិន្ទុ១០០% ជូនមេដាយ
- បាន៨០% ជូនប័ណ្ណសរសើរ
- បាន៥០% ប័ណ្ណទទួលស្គាល់ការងារ

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាផ្លូវមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:២៥នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ១០រោច ខែកទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី

អ្នកធ្វើរបាយការណ៍

ស៊ុត_ថនផាន់